ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ: ០៣៤/១៦ ក.ប/ស.ង.ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរកការងារធ្វើនៅក្រៅប្រទេស

ដោយអនុវត្តតាមអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងគោលបំណងដោះស្រាយការងារជូនប្រជាពលរដ្ឋទាំងពីរភេទ ដែលបច្ចុប្បន្នកំលាំងពលកម្មបានកើនឡើងជារៀងរាល់ឆ្នាំ ក្រៅពីការផ្តល់ការងារក្នុងប្រទេស រាជរដ្ឋាភិបាលក៏បានខិតខំទំនាក់ទំនងរកទីផ្សារការងារនៅក្រៅប្រទេសជូនដល់ប្រជាពលរដ្ឋខ្មែរផងដែរ។ ការចេញទៅធ្វើការនៅក្រៅប្រទេស ពុំត្រឹមតែបានទទួលនូវប្រាក់បៀវត្សខ្ពស់ប៉ុណ្ណោះទេ ពលករយើងថែមទាំងទទួលបាននូវការបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យា ជំនាញវិជ្ជាជីវៈ ភាសា ការយល់ដឹងពីទំនៀមទំលាប់ ការរស់នៅ និងអារ្យធម៌នៃប្រទេសទទួលពលករថែមទៀត។

បច្ចុប្បន្ននេះ ក្រសួងបាននឹងកំពុងបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ម៉ាឡេស៊ី សិង្ហបុរី ជប៉ុន និងសាធារណៈរដ្ឋកូរ៉េ។ កន្លងមកក្រសួងបានពិនិត្យឃើញថា មានក្រុមជនខិលខូចមួយចំនួនបានប្រើល្បិចបោកប្រាស់ប្រជាពលរដ្ឋនាំទៅធ្វើការនៅក្រៅប្រទេសដោយខុសច្បាប់ ហើយទទួលរងនូវការរំលោភបំពានផ្សេងៗ និងរហូតមានគ្រោះថ្នាក់ដល់អាយុជីវិតផងដែរ។

ដើម្បីចៀសវាងការយល់ច្រឡំ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយស សូមជម្រាបជូនប្រជាពលរដ្ឋទាំងពីរភេទ ដែលមានបំណងចង់ទៅធ្វើការនៅក្រៅប្រទេស សូមទំនាក់ទំនងជាមួយទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ ដែលទទួលអាជ្ញាប័ណ្ណពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៤៩ ក្នុងនោះមានអង្គការចំនួន ០២ ដូចខាងក្រោម៖

| N. | Company' Name | Thai | Malaysia | Japan | Singapore |
|---|---|---|---|---|---|
| 1 | Cambodian Labour Supply PTY Ltd | ✓ | ✓ | ✓ | |
| 2 | Human Resource Development Co,. Ltd | ✓ | ✓ | | |
| 3 | Philimore Cambodia Co,. Ltd | ✓ | ✓ | ✓ | ✓ |
| 4 | Human Power Co,. Ltd | ✓ | ✓ | | |
| 5 | Mey Yorn Service Co,. Ltd | ✓ | ✓ | | |
| 6 | Top Manpower Co,. Ltd | ✓ | ✓ | ✓ | |
| 7 | CDM Trading Manpower Co,. Ltd | ✓ | | ✓ | |
| 8 | Chhun Hong Manpower Co,. Ltd | ✓ | ✓ | ✓ | |
| 9 | Ung Rithy Group Co,. Ltd | ✓ | ✓ | | ✓ |
| 10 | STP International Cambodia Public Co,. Ltd | ✓ | | ✓ | |
| 11 | SUCCESS MANPOWER SERVICES Co., Ltd | ✓ | ✓ | ✓ | |
| 12 | C-Pro Co,. Ltd | ✓ | | ✓ | |
| 13 | VC Manpower Co,. Ltd | | ✓ | | |
| 14 | PRO CAST (Cambodia) Co,. Ltd | | | ✓ | |

| | | | | |
|---|---|---|---|---|
| MALCAM Co,. Ltd | ✓ | ✓ | | |
| 168 Manpower Supply Co,. Ltd | ✓ | ✓ | | |
| CECH (CAMBODIA) CO., LTD | ✓ | ✓ | | |
| AJC CO.; LTD | | | ✓ | |
| A.P.T.S.E & C (Cambodia) Resources Co., Ltd | ✓ | ✓ | | |
| Job Asian (Cambodia) Co., Ltd | ✓ | ✓ | ✓ | |
| G P G C International Pte Ltd Co., | ✓ | ✓ | ✓ | |
| Master Cam Human Resource Co., Ltd | ✓ | ✓ | | |
| Unicorn Manpower Co., Ltd. | ✓ | ✓ | | |
| SKMM Investment Group Co.; Ltd | ✓ | ✓ | ✓ | |
| N.A.S MANPOWER CO., LTD | ✓ | ✓ | | |
| I I S Company Ltd | ✓ | ✓ | ✓ | |
| Buruh Cambodian Co., Ltd | ✓ | ✓ | ✓ | |
| CENTURY (CAMBOIDA) MANPOWER Co., Ltd | ✓ | ✓ | ✓ | |
| I.G. CONSULTANT Co., Ltd | ✓ | ✓ | ✓ | |
| K.L.M. MANPOWER CO., LTD | ✓ | ✓ | | |
| C.T. ASIA LABOUR Co., Ltd | ✓ | ✓ | ✓ | |
| P I T T CAMBODIA Co., Ltd | ✓ | ✓ | ✓ | |
| Touch Manak Manpower Supply Co., Ltd | ✓ | ✓ | ✓ | |
| Phnom Penh Labour Supply Co., Ltd | ✓ | ✓ | ✓ | |
| Rice Natural Co., Ltd | ✓ | ✓ | ✓ | |
| Anny Rita Best Manpower Co., Ltd | ✓ | ✓ | ✓ | |
| SOK CHAMNOL Co., Ltd | ✓ | ✓ | ✓ | |
| C.J.T.T TRADING Co., Ltd | ✓ | ✓ | ✓ | |
| B.S.R.O BEST MANPOWER Co., Ltd | ✓ | ✓ | ✓ | |
| I-CEP Phnom Penh Co., Ltd | | | ✓ | |
| Big Bi Imex Group Co., Ltd | ✓ | ✓ | ✓ | |
| KIZUNA HR-ASIA Co, Ltd | | | ✓ | |
| Sok Leap Metrey Co., Ltd | ✓ | ✓ | ✓ | ✓ |
| THE SEABOARD CAMBODIAN DEVELOPMENT CONSTRUCTION CO., LTD | ✓ | ✓ | ✓ | |
| KOBE HUMAN SERVICE (CAMBODIA) CO., LTD | ✓ | | ✓ | |
| C A T M Asia Manpower Cooperation Co., Ltd | ✓ | ✓ | ✓ | |
| KEI KEI (CAMBODIA) HUMAN RESOURCE CO., LTD | ✓ | ✓ | ✓ | |
| NGO ALC | | | ✓ | |
| NGO GCHCC | | | ✓ | |

ចំពោះការដាក់ពាក្យសុំទៅធ្វើការនៅសាធារណៈរដ្ឋកូរ៉េ គឺពុំមានទីភ្នាក់ងារជ្រើសរើសឯកជនយធ្វើការងារនេះទេ មានតែក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មួយគត់ ដែលធ្វើការងារមួយក្រសួងការងារនៃសាធារណៈរដ្ឋកូរ៉េ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋជ្រាប និងសាកសួរព័ត៌មានផ្សេងៗមទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ខាងលើ និងការិយាល័យកេការឲ្យធ្វើ នៃនាយកដ្ឋានរ និងហត្ថពលកម្ម អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខ័ណ្ឌពក រាជធានីភ្នំពេញ នៅរៀងរាល់ម៉ោងធ្វើការ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១៤

រដ្ឋមន្ត្រី

អ៊ិត សំហេង

ឯសហប្រតិបត្តិការអន្តរជាតិ(ដើម្បីជូនជ្រាប)

ទស្សន៍ជាតិ និងឯកជន(ដើម្បីជួយសម្រួល)

បណ្តុះបណ្តាលវិជ្ជាជីវៈ(ដើម្បីអនុវត្ត)